# សេចក្តីប្រកាសព័ត៌មាន

## កិច្ចពិភាក្សាតុមូល "ការធ្វើចំណាកស្រុក ទៅធ្វើការនៅក្រៅប្រទេស"

**ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១១**

**នៅអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា**

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ គ.ស.ន មានកិត្តិយស ជំរាបថា នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ នៅអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជានឹងមានការរៀបចំកិច្ចពិភាក្សាតុមូល ក្រោមប្រធានបទ **"ការធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស"**។

កិច្ចពិភាក្សាតុមូលនេះនឹងមានការអញ្ជើញចូលរួមពីវាគ្មិន ៣រូប គឺៈ

១-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (**បញ្ជាក់នៅពេលក្រោយ**)

២-លោក អន ប៊ុនហាក់ ប្រធានសមាគមជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស

៣-លោក មុំ សុខចារ ប្រធានកម្មវិធី នៃអង្គការជំនួយច្បាប់ដល់ កុមារ និងស្ត្រី

**កិច្ចពិភាក្សាតុមូល** រៀបចំឡើងក្នុងគោលបំណង ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋទូទាំងប្រទេសឱ្យយល់ដឹងពីបញ្ហាកើតឡើងពីការធ្វើចំណាកស្រុករបស់ស្ត្រីខ្មែរទៅធ្វើការនៅក្រៅប្រទេស ជាពិសេសនៅ (ម៉ាឡេស៊ី) និងវិធានការណ៍ដែលរដ្ឋាភិបាល ក៏ដូចជា សង្គមស៊ីវិលបានធ្វើកន្លងមក ក្នុងការស្វែងរកអនុសាសន៍ដើម្បីរួមចំណែករៀបចំផ្តល់ការគាំពារដល់ស្ត្រីទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់។

ក្នុងកម្មវិធីនេះផងដែរ ប្រសិនបើ លោក លោកស្រី និងប្អូននិសិត្សចង់ចូលរួមមានមតិយោបល់ ជជែកពិភាក្សា ឬមានជាចំងល់អាចចោទជាសំនួរផ្សេងៗ ពាក់ព័ន្ធនឹងប្រធានបទនេះបាន។

អាស្រ័យហេតុនេះ សូមអង្គការសង្គមស៊ីវិល និង និស្សិតដែលមានបំណងចូលរួម សូមទាក់ទងមកយើងខ្ញុំ។

***បញ្ជាក់ៈ ចំនួនកន្លែងអ្នកចូលរួមមានកំណត់***

សម្រាប់ព័ត៌មានលំអិតសូមមេត្តាទាក់ទង

**១-លោក ស៊ិន ហុង** មន្ត្រីទំនាក់ទំនង
ទូរសព្ទ័លេខ **០១២ ៣២២ ០១២**
គេហទំព័រៈ www.cpwp.silaka.org
អ៊ីម៉ែលៈ hong@silaka.org

**២-កញ្ញា ហួន សភា**
ទូរសព្ទ័លេខ **០៧៧ ៤៧ ៩០ ១១**
អ៊ីម៉ែលៈ sakphea8@gmail.com